សារព័ត៌មាន
# ខ្មែរម្ចាស់ស្រុក
Khmer Machas Srok News

សារព័ត៌មានចេញផ្សាយប្រចាំថ្ងៃ

ឆ្នាំទី០២ លេខ២៣៤ ចេញផ្សាយថ្ងៃអាទិត្យ_អង្គារ ទី៣១_០២ ខែសីហា_កញ្ញា ឆ្នាំ២០០៨

## មានកិច្ចសន្យាសម្ងាត់អ្វីជាមួយសៀមបានជា ហ៊ុន សែន រុញ ហោ ណាំហុង ឱ្យតាមអង្វរសៀមចរចាទ្វេភាគី?


លោក ហ៊ុន សែន នាយករដ្ឋមន្ត្រីញៀននឹងអំណាចខ្លាំង


លោក ហោ ណាំហុង

ដោយ : គ.អរពិន្ទ

ការផ្ញើឱ្យមានចំណាប់អារម្មណ៍ជាថ្មីទៀតនោះបន្ទាប់ពីសៀមបានដកខ្លួនថយពីការចរចាគ្រោងធ្វើកាលពីថ្ងៃសុក្រ ទី២៩ ខែសីហា ដោយពុំព្រមបញ្ជាក់អំពីមូលហេតុអ្វីឱ្យប្រាកដ និងមិនមានការកំណត់ពេលនៃជំនួប

តទៅទំព័រ៤ ស

## អាជីវកម្មទឹកតូចតាចត្រូវផ្ដាច់ឆ្នាំងអស់ហើយ ដោយសារក្រុមហ៊ុនទឹកស្អាតព្រែកប៉ៅខនស្រ្កាក់សិន


លោក ឈុន ស៊ីរុន


លោក ជា ស៊ីម ប្រធានគណបក្សប្រជាជនកម្ពុជា

ដោយ : វិសាល

ប្រជាពលរដ្ឋដែលធ្លាប់ប្រកបអាជីវកម្មបូមទឹកលក់ នៅឃុំព្រែកព្នៅ ស្រុកពញាឮ ខេត្តកណ្ដាល គ្រាន់នឹងបានប្រាក់កម្រៃចិញ្ចឹមជីវិតនោះ ឥឡូវនេះត្រូវផ្ដាប់ឆ្នាំងជាស្ថាពរហើយ ដោយសារអំណាចបារមីនៃក្រុម

តទៅទំព័រ២ ឈ

## ឡៅ ម៉ុងហៃ : រដ្ឋាភិបាលខ្លាំងឬខ្សោយមិនមែនស្ថិតនៅលើការបង្កើនចំនួនមន្ត្រីតរជើងគ្នាទេ


លោកបណ្ឌិត ឡៅ ម៉ុងហៃ

ដោយ : គ.អរពិន្ទ

ពេលដែលគណបក្សប្រជាជន *ហ៊ុន សែន* កំពុងគិតគូររង់ចាំពេលវេលានឹងអាលបង្កើតរដ្ឋាភិបាលអាណត្តិទី៤ ឱ្យ *ហ៊ុន សែន* បានធ្វើនាយករដ្ឋមន្ត្រី ដោយមានសមាសភាពពង្រីកចំនួនមន្ត្រីរដ្ឋាភិបាលឡើងដល់

តទៅទំព័រ២ គ

## បើសហគមន៍អន្តរជាតិនៅតែមិនជួយដោះស្រាយទៀត គឺដូចទុកឱ្យប្រជាធិបតេយ្យនៅកម្ពុជាស្លាប់ទៅយ៉ាងវេទនាដែរ


លោក សម រង្ស៊ី


លោក កឹម សុខា


លោក ចច ដាប់ប៊ែលយូប៊ុស


លោក បាន គីមូន


ទិដ្ឋភាពនៅក្នុងពេលរាប់សន្លឹកឆ្នោតកន្លងមក


លោក អ៊ឹម សួស្ដី


លោក ឯក សំអុល

ដោយ : យុទ្ធ ពន្យ

បន្ទាប់ពីក្រុមប្រឹក្សាធម្មនុញ្ញបានបដិសេធចោលនូវពាក្យបណ្ដឹងរបស់គណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សព្រមទាំងប្រកាសបិទផ្លូវតវ៉ាមក គណបក្សប្រឆាំងទាំងពីរក៏បានសម្រេចបើកការតស៊ូតាមផ្លូវច្បាប់ទៅដល់សហគមន៍អន្តរជាតិជាបន្តទៀត ដើម្បីការពារសិទ្ធិស្របច្បាប់របស់ប្រជាពល

តទៅទំព័រ៤ ម

## ជិត៥ឆ្នាំហើយដែលឃាតកបាញ់ប្រហារតារាចម្រៀង ទូច ស៊ុននិច នៅតែរស់ក្រៅសំណាញ់ច្បាប់


រូបគំនូរព្រាងមុខជនសង្ស័យដែលជាឃាតកបាញ់ប្រហារនាង ទូច ស៊ុននិច


តារាចម្រៀង ទូច ស៊ុននិច ពេលបញ្ជូនមកដល់មន្ទីរពេទ្យរុស្ស៊ី

ដោយ : គ.រដ្ឋា

បើគិតមកដល់ថ្ងៃនេះ ការបាញ់ប្រហារតារាចម្រៀង *ទូច ស៊ុននិច* បានកន្លងទៅអស់រយៈពេលជិត៥ឆ្នាំហើយ តែឃាតកដៃដល់ក្នុងអំពើឃាតកម្មនេះនៅតែរស់ក្រៅសំណាញ់ច្បាប់ដដែល ។

ប៉ុន្តែបើសម្រាប់ជីវិតដែលនៅសល់របស់កញ្ញារងគ្រោះ *ទូច ស៊ុននិច* វិញ ត្រូវបានក្រុម

តទៅទំព័រ២ ន

## ចោរសៀមនិងពួកលោភលន់ស៊ីភីភីអុកឡុកកម្ពុជា

ដោយ : សច្ចៈ

រយៈពេល ជាងមួយខែនេះ ទាហានឈុតខ្មៅសៀម បានទន្ទ្រានឈ្លានពាន អាណាចក្រខ្មែរជាច្រើនកន្លែង ពិសេសនៅតំបន់ ក្បែរប្រាសាទព្រះវិហារ តំបន់អន្លង់វែង តំបន់ប្រាសាទតាមាន់ធំ និងភូមិជុំបគិរីខាងកើត នៃខេត្តឧត្តរមានជ័យជា

តទៅទំព័រ៣ ហ

## ខ្មែរមានឱកាសយកប្រៀបលើចោរសៀមហើយ


នាយករដ្ឋមន្ត្រីសៀម សាម៉ាក់


វិមានរដ្ឋាភិបាលសៀមត្រូវបានហ៊ុំព័ទ្ធដោយបាតុករសៀម

ដោយ : រតនៈ

ភាពច្របូកច្របល់ របស់ពួកប្រឆាំងរដ្ឋាភិបាលសៀមយ៉ាងតានតឹង រយៈពេលប៉ុន្មានថ្ងៃនេះ វាដូចផ្ដល់ឱកាសឱ្យភាគីកម្ពុជាដណ្ដើមយកប្រៀប និងប្រើឱកាសដ៏ល្អនេះ ដើម្បីដោះស្រាយបញ្ហា នៅតាមព្រំដែន

តទៅទំព័រ២ ជ

ស្រូវទុំ ភំរងកែវ

ភោជនីយដ្ឋាន **កំរងកែវ** អតីតភោជនីយដ្ឋាន **ស្រូវទុំ** ឥឡូវនេះបានបើកឡើងវិញហើយ ដោយប្ដូរឈ្មោះថា **កំរងកែវ** ដោយប្ដូរទាំងចៅកែ ។

លោក មាស គន្ធី ដែលជាអតីតចៅកែភោជនីយដ្ឋាន **ស្រូវទុំ** ត្រូវបានផ្លាស់ប្ដូរដោយចៅកែថ្មីដែលមានជំនាញពិសេសល្អលើសចៅកែចាស់ (ស្រូវទុំ) ទ្វេដង ពីព្រោះចៅកែថ្មី និងចុងភៅសុទ្ធតែមានបទពិសោធយូរឆ្នាំ និងមានជំនាញច្បាស់លាស់ ។

អាស្រ័យហេតុនេះ សូមអញ្ជើញភ្ញៀវទាំងអស់មកភ្លក្សរស់ជាតិដែលជាស្នាដៃរបស់ចៅកែ និងចុងភៅថ្មី និងមានការរៀបចំយ៉ាងពិសេសសម្រាប់ភ្ញៀវទាំងអស់ដែលបានអញ្ជើញមកពិសានៅភោជនីយដ្ឋានយើងខ្ញុំ ។

**បញ្ជាក់** : ចំពោះភ្ញៀវដែលអញ្ជើញមកពិសានៅភោជនីយដ្ឋាន **កំរងកែវ** យើងខ្ញុំដោយភ្ជាប់ជាមួយនឹងប័ណ្ណជូនដំណឹងក្នុងសារព័ត៌មានខ្មែរម្ចាស់ស្រុកនេះ យើងខ្ញុំនឹងបញ្ចុះតម្លៃជូន១០% ។

អាស័យដ្ឋាន ផ្ទះលេខ៤២ ផ្លូវ២៨៩ កែងសាលាទួលគោក "ពៅអ៊ុំ"

ដំណឹងពិសេសដ៏អស្ចារ្យ

ពីលោកគ្រូ **ហោ លីម** ព្យាបាលតាមរបៀបម៉ាស្សា លាប រឹត ស្អំ ថ្នាំបុរាណខ្មែរ ធូរស្បើយក្នុង រយៈពេល **១ម៉ោង (មិនធូរស្បើយមិនគិតលុយ)** នូវជំងឺមនុស្សចាស់ចុកចាប់ក្នុងរាងកាយ, ឈឺក្បាលជាយូរឆ្នាំក្ដី, ឈឺជង្គង់, ឈឺសន្លាក់ដៃ សន្លាក់ជើង, រោយឆ្អឹងខ្នង, តឹងច្រមុះ, តឹងទ្រូង, ថប់ដង្ហើម, ញ័រទ្រូង, ទល់ឆ្អល់ក្នុងពោះ, ពិបាកបត់ជើងតូចធំ, ជាពិសេសជំងឺ១០០មុខក្នុង រាងកាយ ។ល។ **ផ្នែកសម្រស់ :** សង្វាពោះក្រាស់ ជាំមុខ គ្មានដោះ ឬដោះស្បែត ព្យាបាល យ៉ាងស័ក្ដិសិទ្ធ។

ទីតាំងផ្ទះលេខ០៧៧ **ហោ លីម ថៃសមួស្ស** ច្រកចូលផ្លូវមានដំបូល ជាប់របងស្អាតចាស់ សង្កាត់ស្រះចក ខណ្ឌដូនពេញ

ទូរស័ព្ទទំនាក់ទំនង : 012 363 331, 016 719 616, 012 801 863, 016 719 613

### *បរិយាយថ្ងៃនេះ*

## គណបក្សប្រជាជន ហ៊ុន សែន ប្លន់យកអាសនៈសភាគណបក្សប្រឆាំងបានឬអត់?

ដោយ : ហង្ស ច្រាផ្លា

នេះគឺជាសំណួរដែលកើតមានជាចម្ងល់របស់សាធារណជនដែលចង់ដឹងថា តើគណបក្សប្រជាជន ហ៊ុន សែន ដែលបានលួចសន្លឹកឆ្នោតយ៉ាងហូរហៀរដោយសារការជួយរបស់ គ.ជ.ប និងអាជ្ញាធរដែនដីជាឧបករណ៍របស់ខ្លួនឱ្យគណបក្សនេះតម្លើងតួលេខបំប៉ោងរហូតដល់ខ្លួនបានអាសនៈសភារហូសហេតុដល់៩០នេះ តើគណបក្សរបស់ ហ៊ុន សែន ហ្នឹងអាចប្លន់

តទៅទំព័រ៤ ក

Tel: 012 850 690 / 017 360 678 , Fax: 023 987 411

តមកពីទំព័រ១ ឈ

ហ៊ុនទឹកស្អាតមួយយីហោ "*ព្រៃគប់ខនស្ត្រាក់សិន*" ដែលត្រូវដងត្រូវផ្លែជាមួយលោក *ឈុន ស៊ីរុន* ចៅហ្វាយខេត្តកណ្តាល។

មានសេចក្តីរាយការណ៍មួយបានឱ្យយើងដឹងថា ប្រជាពលរដ្ឋចំនួន៣នាក់ដែលរួមមានឈ្មោះ *ណែម ហុក, ខាត់ ខែម* និង *ទេព វណ្ណឌី* ដែលធ្លាប់ប្រកបអាជីវកម្មបូមទឹកលក់គ្រាន់នឹងចិញ្ចឹមជីវិតតាំងពីយូរណាស់មកហើយនោះ ត្រូវបានចៅហ្វាយខេត្តកណ្តាលឈ្មោះ*ឈុន ស៊ីរុន* ចេញលិខិតមួយច្បាប់លេខ៣០៩ ស.ជ.ណ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៨ បញ្ជាឱ្យចៅហ្វាយស្រុកពញាឮចុះមកផ្អាកអាជីវកម្មបូមទឹកលក់របស់ពួកគាត់ដោយមិនសមហេតុផលទាល់តែសោះ។

ដោយសារតែលោកចៅហ្វាយខេត្តកណ្តាល *ឈុន ស៊ីរុន* អាងអំណាចដ៏មហិមារបស់ខ្លួនទៅជាន់កអាជីវករតូចតាចដែលគ្រាន់តែរកមួយថ្ងៃសម្រាប់រស់មួយថ្ងៃបែបនេះហើយ ទើបអាជីវករដ៏កម្សត់ទាំង៣នាក់នេះសម្រេចចិត្តប្តឹងទៅលោក *ជា ស៊ីម* ប្រធានគណបក្សប្រជាជន និងជាប្រធានព្រឹទ្ធសភា ដើម្បីឱ្យជួយអន្តរាគមន៍ក្នុងរឿងនេះផង។

តាមពិតទៅសាច់រឿងនេះត្រូវបានគេបង្ហើបឱ្យយើងដឹងថា វាបណ្តាលមកពីលោក *ឈុន ស៊ីរុន* មិនព្រមឈរឱ្យចំចន្លោះកណ្តាលនៃបញ្ហាទើបធ្វើឱ្យក្រុមហ៊ុនទឹកស្អាតយីហោ "*ព្រៃគប់ខនស្ត្រាក់សិន*" មានឥទ្ធិពលយ៉ាងលើសលប់ស្ទើរតែក្លាយជាក្រុមហ៊ុនផ្តាច់មុខនៅស្រុកពញាឮទៅហើយ។ សួរថា ឯណាទៅគោលនយោបាយទីផ្សារសេរីរបស់រដ្ឋាភិបាលកញ្ចប់ *ហ៊ុន សែន* នោះ ?

ឥឡូវនេះប្រភពព័ត៌មានពីអាជីវករតូចតាចទាំង៣នាក់នៅឃុំព្រៃព្នៅនោះបានឱ្យដឹងថា "*លោក ជា ស៊ីម បានចារបញ្ជូនទៅឱ្យលោក ឈុន ស៊ីរុន ចៅហ្វាយខេត្តកណ្តាលឱ្យជួយដោះស្រាយហើយ តែលោក ឈុន ស៊ីរុន មិនបានយកភ្នែកមើលចំណារលោក ជា ស៊ីម ប្រធានគណបក្សប្រជាជននោះទេ។លុះដល់មានការសួរនាំទៅ បែរជាលោក ឈុន ស៊ីរុន ដ៏មហិមានិយាយថា គាត់រវល់ណាស់គ្មានពេលមើលចំណារនោះទេ* *Sic!*។

បានសេចក្តីថា លោក *ជា ស៊ីម*ប្រធានគណបក្សប្រជាជនពិតជាពុំមានអំណាចអ្វីមែនទើបបានជាឋានៈត្រឹមលោក *ឈុន ស៊ីរុន* ចៅហ្វាយខេត្តមួយសោះ ហ៊ានថ្លើមធំយ៉ាងដូច្នេះ។

តំណាងអាជីវករបូមទឹកលក់ម្នាក់បាននិយាយរៀបរាប់ថា ពួកគាត់បានធ្វើអាជីវកម្មចែកចាយទឹកនេះតាំងពីឆ្នាំ១៩៩៩មកម្ល៉េះ ដោយលក់ក្នុងតម្លៃសមរម្យល្មមនឹងប្រជាពលរដ្ឋទទួលយកបាន។

តំណាងអាជីវករដដែលនេះបានបន្តទៀតថា "*ចាប់តាំងពីឆ្នាំ២០០០មក ក៏ស្រាប់តែមានក្រុមហ៊ុនទឹកស្អាតមួយឈ្មោះព្រៃគប់ខនស្ត្រាក់សិន បានមកវិនិយោគនៅស្រុកពញាឮ ក៏ចាប់ផ្តើមមានបញ្ហាជាមួយពួកគាត់ដែលជាអាជីវករតូចតាចតែម្តងទៅ*"។

យោងតាមពាក្យបណ្តឹងទៅលោក *ជា ស៊ីម* ប្រធានគណបក្សប្រជាជន តំណាងអាជីវករទាំង៣នាក់ដែលរួមមានឈ្មោះ *ទេព វណ្ណឌី* ជាម្ចាស់អាជីវកម្មភូមិព្រៃកព្នៅ, ឈ្មោះ *ខាត់ ខែម* ម្ចាស់អាជីវកម្មភូមិផ្សារលិច,ឈ្មោះ*ណែម ហុក*ម្ចាស់អាជីវកម្មភូមិកណ្តាល បានអះអាងថា "*ក្រុមហ៊ុនទឹកស្អាតព្រៃគប់ខកស្ត្រាក់សិននេះបានឃុបឃិតផ្សំគំនិតជាមួយមន្ទីរឧស្សាហកម្មរ៉ែ និងថាមពលខេត្តកណ្តាល ក៏ដូចជាចៅហ្វាយខេត្តកណ្តាលផងដែរ ទើបកើតចេញជាលិខិតផ្អាកការធ្វើអាជីវកម្មរបស់ពួកគាត់រហូតមកដល់សព្វថ្ងៃនេះ*"។

"*ខ្មែរម្ចាស់ស្រុក*" មិនលំអៀងទៅលើភាគីណាមួយនោះទេ តែគួរអាជ្ញាធរខេត្តកណ្តាលសម្លឹង និងដោះស្រាយឱ្យចំបញ្ហាទើបជាការប្រសើរ។ ព្រោះបើអស់លោកបើកដៃឱ្យក្រុមហ៊ុនធំបានរស់ដោយសុខស្រួល រួចជាន់ពន្លិចពួកអាជីវករតូចតាចឱ្យដាច់ខ្យល់ប៉ិតបែបនេះ គឺជារឿងមួយអយុត្តិធម៌ណាស់ដែលតម្រូវឱ្យធ្វើការពិចារណាសាជាថ្មីឡើងវិញ។

ទន្ទឹមនេះប្រជាពលរដ្ឋដែលធ្លាប់ប្រើប្រាស់ទឹករបស់ម្ចាស់អាជីវកម្មភូមិព្រៃកព្នៅ, ម្ចាស់អាជីវកម្មភូមិផ្សារលិច និងម្ចាស់អាជីវកម្មភូមិកណ្តាល នៃឃុំព្រៃកព្នៅ ស្រុកពញាឮ ខេត្តកណ្តាល បានផ្តិតមេដៃគាំទ្រដល់ការធ្វើអាជីវកម្មតូចតាចទាំង៣កន្លែងនេះផងដែរ។

ដូច្នេះគួរតែលោក *ឈុន ស៊ីរុន* ចៅហ្វាយខេត្តកណ្តាលកុំធ្វើអ្វីឱ្យហួសហេតុពេក ព្រោះការបិទអាជីវកម្មខ្នាតតូចតាចដើម្បីទុកឱកាសឱ្យអាជីវកម្មខ្នាតធំគ្រាក់ៗរស់ដោយចំហបែបនេះ វាមិនខុសអ្វីពីបង្កើនភាពក្រីក្រដល់ប្រជាពលរដ្ឋខ្មែរ ប្រឆាំងនឹងនយោបាយរបស់លោក *ហ៊ុន សែន* ដែលតែងតែសូត្រយ៉ាងរត់មាត់ថា "*កាត់បន្ថយភាពក្រីក្រ*" នោះទេ។

យើងយល់ថាការធ្វើអាជីវកម្មបូមទឹកលក់ដោយអាជីវករតូចតាចនៅឃុំព្រៃកព្នៅ មិនមានអ្វីដែលត្រូវប៉ះពាល់ទៅដល់ក្រុមហ៊ុនទឹកស្អាត "*ព្រៃគប់ខនស្ត្រាក់សិន*" ស្អីគេនោះឡើយ។ ព្រោះសម័យនេះជាសម័យមួយដែលបានប្រកាន់យកនូវរបបទីផ្សារសេរីទៅហើយមិនអាចឱ្យក្រុមហ៊ុនមួយហ្នឹងរកស៊ីទឹកផ្តាច់មុខនៅស្រុកពញាឮបានជាដាច់ខាត។

យើងសូមឱ្យប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តកណ្តាលក៏ដូចជាលោកចៅហ្វាយស្រុកពញាឮ ព្រមទាំងលោក *ឈុន ស៊ីរុន* ចៅហ្វាយខេត្តកណ្តាលមេត្តាបើកភ្នែកពិនិត្យ និងដោះស្រាយតាមសំណូមពរ របស់ម្ចាស់អាជីវកម្ម និងប្រជាពលរដ្ឋជាបន្ទាន់ផង ប្រសិនបើអស់លោកមិនចង់ឱ្យរឿងនេះកាន់តែវែងឆ្ងាយតទៅទៀត៕

តមកពីទំព័រ១ គ

ប្រមាណ៤០០នាក់នោះ មន្ត្រីអង្គការសង្គមស៊ីវិលបានធ្វើការរិះគន់របៀបរបបការងារបង្កើនបន្ទុកចំណាយថវិការរដ្ឋ ដូច្នេះជាការជិះជាន់ប្រជារាស្ត្រ។

បណ្ឌិត *ឡៅ ម៉ុងហៃ* បាននិយាយថា "*រដ្ឋាភិបាលខ្លាំង ឬមិនខ្លាំង មិនសម្រេចនៅលើចំនួននោះទេ។ ដូចព្រះរាជាណាចក្រអង់គ្លេស រដ្ឋាភិបាលគេមានរដ្ឋមន្ត្រីតែប្រមាណជាង១០នាក់។ ហើយរដ្ឋមន្ត្រី១០ទៅ១៥នាក់នោះគេប្រជុំគ្នាដោយរដ្ឋមន្ត្រីមានតែប៉ុន្មាននាក់។រដ្ឋាភិបាលហ្នឹងបានហៅថាខ្លាំង*"។

ការថ្លែងនេះជាការសំដៅរិះគន់ដល់គម្រោងរបស់គណបក្សប្រជាជន *ហ៊ុន សែន* ដែលនឹងបង្កើតរដ្ឋាភិបាលអាណត្តិទី៤ ដោយបង្កើនចំនួនមន្ត្រីរដ្ឋាភិបាលធំនិងច្រើនជាងកាលសម័យរដ្ឋាភិបាលអាណត្តិទី៣ទៅទៀត។ ហើយរបៀបនេះមន្ត្រីគណបក្សប្រជាជនបាននិយាយអួតអាងថាជាការប្រមូលធនធានមនុស្ស និងបង្កើនប្រសិទ្ធភាពការងារបំរើការរដ្ឋ។

ប៉ុន្តែខុសពីនេះ អ្វីដែលជាសេចក្តីថ្លែងរបស់មេដឹកនាំគណបក្សប្រជាជន ត្រូវបានពួកអ្នកសង្កេតការណ៍ និងមន្ត្រីជំនាញនិយាយថាជាការគ្រាន់តែរកវិធីបង្កើនចំនួនអាសនៈសភាបែងចែកគ្នាជារបៀបដោះស្រាយបញ្ហាជម្លោះផ្ទៃក្នុងនៃការច្រណែនគ្នាអំពីការបានឬមិនបានអាសនៈតំណែងក្នុងរដ្ឋាភិបាលនោះ។

ហើយនេះក៏កើតមានឡើងនៅក្រោយពីគណបក្សប្រជាជន *ហ៊ុន សែន* បានគៀងគរប្រមែប្រមូលពួកមន្ត្រីឱកាសនិយមរត់ចេញពីគណបក្សសមរង្ស៊ីក្តី ពីហ៊្វុនស៊ិនប៉ិចក្តីដើម្បីក្នុងបំណងឱ្យបំបែកគណបក្សប្រឆាំងនឹងអាលឱ្យគណបក្សប្រជាជនធានានូវការរក្សាតំណែងអំណាចតទៅមុខទៀត។

ហើយដូច្នេះអ្វីៗជាការបង្កើនចំនួនមន្ត្រីក្នុងរដ្ឋាភិបាលអាណត្តិទី៤នេះក៏ត្រូវគេមើលឃើញថាមានបំណងធំគឺដើម្បីរកកន្លែងឱ្យពួកអ្នករត់ចោលជួរទាំងឡាយអង្គុយ ហើយក៏ជាគោលដៅធំនៃផែនការនយោបាយរបស់ស៊ីភីភី *ហ៊ុន សែន* ក្នុងការរក្សាអំណាចតាមរយៈការពង្រីកពង្រឹង

តទៅទំព័រ៣ គ

តមកពីទំព័រ១ ឌ

ឱ្យបានចប់សព្វគ្រប់ហើយ ។

ភាគីកម្ពុជា និងសៀមបានលុបចោល គំរោងនៃការចរចានៅខេត្តសៀមរាបដែលគ្រោងធ្វើឡើង កាលពីថ្ងៃទី២៩ ខែសីហា ២០០៨ ។ ការបរាជ័យនេះ ធ្វើឡើងតាមសំណើរបស់ភាគីសៀម ដែលពួកគេគ្រាន់តែប្រើពាក្យថាមានបញ្ហារឹករវរនៅក្នុងប្រទេសសៀម ។ឯភាគីកម្ពុជាវិញ ក៏បានយល់ព្រម, ហើយមិនបានប្រកាសអំពីកាលកំណត់នៃការចាប់ផ្តើមនិយាយគ្នានៅ ថ្ងៃណាទៀតនោះទេ ។ ការដែល ភាគីខ្មែរយល់ព្រមផ្អាកការចរចា ជាមួយសៀម ដោយសំអាងថា សៀមមានបញ្ហាផ្ទៃក្នុងនោះវាដូចជាសៀមមើលងាយខ្មែរ សម្បើមណាស់ គឺមើលងាយ តាំងពីថ្នាក់លើដល់ថ្នាក់ក្រោម ដែលគ្រាន់តែពួកគេឈ្លោះគ្នា ក៏ឈ្លានពានខ្មែរបានដែរទៅហើយនោះ ។ ចុះបើសៀមវារួបរួមគ្នា ហើយរំលោភបូរណ ភាពទឹកដីខ្មែរ តើខ្មែរយើង នឹងត្រូវបាត់បង់ដល់កម្រិតណា ?

ក្រោយពីបញ្ចប់ នៃកិច្ចប្រជុំរបស់គណៈរដ្ឋមន្ត្រី កាលពីថ្ងៃសុក្រលោក*ហ៊ុន សែន* បានប្រាប់អ្នកកាសែតថា លោកនឹងអោយលោក*ហោ ណាំហុង* រដ្ឋមន្ត្រីក្រសួងការបរទេសខ្មែរធ្វើការទាក់ទងគ្នា ជាមួយនឹងរដ្ឋមន្ត្រីការបរទេសសៀម ដើម្បីបន្តពិភាក្សាគ្នាទៀត ។ លោក *ហ៊ុន សែន* ក៏បានអះអាងផងដែរថា សៀមមិនអាចយកប្រទេសកម្ពុជា ធ្វើជាចំណាប់ខ្មាំងនៃជម្លោះផ្ទៃក្នុង របស់ខ្លួនបានទេ ។

ទោះយ៉ាងណា ភាគីសៀមបានអះអាង កាលពីថ្ងៃសុក្រដែលបណ្តាញព័ត៌មាន បានដកស្រង់សម្តីផ្លូវការថា ការលុបចោលគំរោង នៃការចរចនេះគឺបណ្តាលមកពីភាគីកងទ័ព នៃប្រទេសទាំងពីរ មិនបានត្រៀមខ្លួនជាមុនឱ្យបានល្អ។ ប៉ុន្តែការដោះសារបស់សៀមនេះ ត្រូវបានអ្នកច្បាប់ខ្មែរ និយាយថា មកពីខ្មែរអន់ ហើយបណ្តោយឱ្យអ្នកដែលគ្មានសមត្ថភាពធ្វើការជាមួយសៀម ។

អ្នកច្បាប់ខ្មែរ បានបន្តទៀតថា ឆ្លៀតពេលដែលសៀម កំពុងមានបញ្ហាផ្ទៃក្នុង ភាគីខ្មែរគួរប្រើឱកាសនេះ ដោះស្រាយឱ្យរួចរាល់បញ្ហាព្រំដែនជាមួយសៀម, ហើយបើសិនជាសៀមដោះស្រាយបញ្ហាផ្ទៃក្នុងគេចប់ ទើបដោះស្រាយ ជាមួយខ្មែរនោះ គឺសៀមប្រមូលផ្តុំទាំងអ្នកចេះដឹងទាំងអ្នកជាតិនិយម និង ទាំងអ្នកមានមហិច្ឆតាចង់បានដីខ្មែរនោះ នឹងធ្វើការគាបសង្កត់ខ្មែរលើសដើម ។ ដូច្នេះ ភាគីកម្ពុជា ដែលលោក*ហ៊ុន សែន*ចូលចិត្តឱ្យអ្នកគ្មានសមត្ថភាព ទៅចរចាជាមួយសៀមនោះ នឹងមិនបានលទ្ធផលអ្វីឡើយ ។

ពាក់ព័ន្ធនឹងការចរចា ចំនួន៦ដងហើយ មិនទទួលបានលទ្ធផលអ្វីនោះ បានធ្វើអោយទាហានខ្មែរ ដែលកំពុងឈរជើងនៅតំបន់ ក្បែរប្រាសាទព្រះវិហារខ្លះ ប្រាប់*ខ្មែរម្ចាស់ស្រុក* កាលពីព្រឹកម្សិលមិញថា ពួកគេគ្មានជំនឿ ទៅលើការចរចាទេ ពីព្រោះចោរសៀមនេះ វាខូចទាំងថ្នាក់លើ ខូចទាំងពួកទាហានឈុតខ្មៅ គឺចង់បានទឹកដីខ្មែរដោយគ្មានខ្មាសអៀន ។ ទាហានខ្មែរដដែល ដែលបានមកលេងប្រពន្ធកូន នៅទីក្រុងភ្នំពេញ បានអោយដឹងទៀតថា ទឹកចិត្តទាហានខ្មែរ មានភាពអង់អាច ហើយអោយតែថ្នាក់លើបញ្ជានឹងធ្វើការព្រមានពួកចោរសៀមឱ្យស្គាល់ដៃម្តង កុំឱ្យពួកវាមើលងាយខ្មែរ ឈ្លានពានខ្មែរនិងនិយាយបាតដៃខ្នងដៃជាមួយខ្មែរទៀត ។

មហាជនខ្មែរ សួរលោក*ហ៊ុន សែន* នាយករដ្ឋមន្ត្រីខ្មែរ ខ្លាំងបានតែជាមួយខ្មែរគ្នាឯងថាចុះបើសៀម អូសបន្លាយបញ្ហាផ្ទៃក្នុងវាមួយឆ្នាំទៀត ឬដប់ឆ្នាំទៀតនោះ, ភាគីកម្ពុជានៅតែអង្គុយរង់ចាំ ឱ្យភាគីសៀមគេដោះស្រាយបញ្ហាផ្ទៃក្នុងគេចប់ ទើបទៅចរចាឬយ៉ាងណា និងថាអោយចោរសៀមទាំងនោះ បន្តឈ្លានពានខ្មែរ រហូតដប់ឆ្នាំទៀតដែរឬ ?

មហាជនខ្មែរ បាននិយាយទៀតថា លោក*ហ៊ុន សែន* និងឧត្តមសេនីយ៍ យោធាខ្មែរភាគច្រើន ខ្លាំងបានតែជាមួយប្រជាពលរដ្ឋខ្មែរ, ហើយបើជាមួយចោរឈ្លានពានសៀមវិញ គឺស្ងាត់ដូចចោរលួចសេះ គឺបានត្រឹមតែនិយាយថា ភាពអត់ធ្មត់ឱ្យបានខ្ពស់ ដែលភាពអត់ធ្មត់របស់លោក*ហ៊ុន សែន* នេះបានធ្វើឱ្យ ចោរសៀមបានចិត្ត និងបន្តរំកិលព្រំដែន ចូលក្នុងដីខ្មែរជាច្រើនកន្លែងទៀត ។

ដូច្នេះហើយបានជាអ្នកច្បាប់ខ្មែរនិយាយថា កម្ពុជាមានឱកាសក្នុងការដោះស្រាយបញ្ហាព្រំដែនជាមួយសៀមហើយ គឺមិនត្រូវផ្តល់ឱកាស អោយពួកឈ្លានពានសៀម ប្រើបញ្ហាផ្ទៃក្នុងរបស់គេ ដើម្បីឈ្លានពានបូរណភាពទឹកដីខ្មែរនោះទេ៕

តមកពីទំព័រ១ ន

គ្រួសារអត្ថាធិប្បាយថាចំណាយប្រាក់អស់ជិត៣០ម៉ឺនដុល្លារទៅហើយ តែកញ្ញា *ទូច ស៊ុននិច*ប្រៀបដូចជាមនុស្សរុក្ខជាតិ និងមិនអាចនិយាយស្តីចឡើយ។

គួររំលឹកថា តារាចម្រៀង *ទូច ស៊ុននិច* ត្រូវបានឃាតកមិនស្គាល់មុខធ្វើការបាញ់ប្រហារយ៉ាងព្រៃផ្សៃនៅទីក្រុងភ្នំពេញទាំងកណ្តាលថ្ងៃត្រង់កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៣។ ហើយការបាញ់ប្រហារនោះបានកើតឡើងនៅត្រង់ចំណុចមុខហាងលក់ផ្កាឃី ហោខ្យាដ៉ីរី ដែលស្ថិតនៅតាមបណ្តោយផ្លូវព្រះមុនីវ៉េត។

នៅក្នុងអំពើបាញ់ប្រហារដ៏ឃោរឃៅនោះដែរ បានធ្វើឱ្យអ្នកម្តាយរបស់កញ្ញា *ទូច ស៊ុននិច* ឈ្មោះ *គីម ស៊ីនួន* អាយុ៥៩ឆ្នាំត្រូវស្លាប់បាត់បង់ជីវិតក្រោយពីបញ្ជូនទៅដល់មន្ទីរពេទ្យកាល់ម៉ែតបានប្រហែលជាកន្លះម៉ោងប៉ុណ្ណោះ។

ចំណែកកញ្ញា *ទូច ស៊ុននិច* វិញត្រូវបានប្អូនប្រុសរបស់នាងដឹកបញ្ជូនទៅសង្គ្រោះបន្ទាន់នៅឯមន្ទីរពេទ្យព្រះបាទនរោត្តម សីហនុ (ពេទ្យរុស្ស៊ី)។ ហើយក្រោយពីការជួយសង្គ្រោះអស់រយៈពេលជិត១៨ម៉ោងមក នាងក៏ត្រូវបានគេបញ្ជូនទៅមន្ទីរពេទ្យបំរុងរ៉ាត់នាទីក្រុងបាងកកប្រទេសសៀម។

ការព្យាបាលនៅមន្ទីរពេទ្យបំប៉ុងរ៉ាត់នេះ គឺបានប្រព្រឹត្តទៅតែមួយរយៈពេលប៉ុណ្ណោះក្រោមការជួយឧបត្ថម្ភជាថវិកាខ្លះៗពីរដ្ឋាភិបាលលោក *ហ៊ុន សែន* ។ ហើយនៅទីបំផុតកញ្ញា *ទូច ស៊ុននិច*ក៏បានទៅព្យាបាលនៅសហរដ្ឋអាមេរិកក្រោមការជួយឧបត្ថម្ភគាំទ្រដោយសប្បុរសជនខ្មែរនៅអាមេរិក។

អស់រយៈពេលជិត៥ឆ្នាំមកនេះ អាជ្ញាធរនៃរដ្ឋាភិបាលលោក *ហ៊ុន សែន* នៅតែស្វែងរកមុខឃាតកដដែលមិនឃើញទៀត។ហើយសូម្បីតែអាជ្ញាធរមានសមត្ថកិច្ចបានគូរគំនូរព្រាងរូបឃាតករួចហើយនោះ ក៏នៅតែរកមិនឃើញ ដដែល ពោលគឺឃាតកដ៏យង់ឃ្នងនោះត្រូវរស់នៅក្នុងលំហសេរីភាពយ៉ាងសុខស្រួលបំផុត។

កាលពីខែកក្កដាកន្លងទៅ សាច់ញាតិកញ្ញា *ទូច ស៊ុននិច* បានរៀបរាប់ថា ស្ថានភាពជំងឺកញ្ញា*ទូច ស៊ុននិច* ដែលមកដល់តំណាក់ចុងក្រោយនេះ ហាក់ដូចជាមានសង្ឃឹមតិចណាស់។

ប្រភពដដែលបានឱ្យទស្សនាវដ្តីក្នុងស្រុកមួយដឹងទៀតថា មុខរបួសឆ្អឹងកងត្រង់បំពង់កបានរលេះរលួយឈាមសស៊ីឈាមក្រហម ធ្វើឱ្យអ្នករបួសមិនអាចហើបមាត់និយាយបានទេ ពោលគឺគ្រាន់តែអាចស្តាប់បានប៉ុណ្ណោះ។ ចំណែកដៃជើងវិញកំរើកលែងរួចទៅហើយ។

ប្រភពបានបន្តទៀតថាសព្វថ្ងៃនេះរាល់ការបញ្ចុកចំណីអាហារ និងការបន្ទោរបង់ត្រូវប្រើប្រាស់ដោយឧបករណ៍ម៉ាស៊ីនទាំងអស់ ដែលមើលទៅឃើញគួឱ្យវេទនាភ្នែកសម្បើមណាស់។

សាច់ញាតិកញ្ញា *ទូច ស៊ុននិច*ដដែលនេះបានបញ្ជាក់ច្បាស់ថា "*ពេលដែលបញ្ជូន ទូច ស៊ុននិច ចេញពីមន្ទីរពេទ្យបំរុងរ៉ាត់ក្រុងបាងកកប្រទេសសៀមទៅបន្តព្យាបាលនៅឯសហរដ្ឋអាមេរិកគឺក្រុមគ្រូពេទ្យនៅអាមេរិកបាននិយាយថា យ៉ាងយូរ៤ឆ្នាំប៉ុណ្ណោះ ទូច ស៊ុននិច នឹងបានដឹងលទ្ធផលខ្លះៗហើយ។តែវាជារឿងមួយគួរឱ្យសោកស្តាយណាស់ ព្រោះជិត៥ឆ្នាំទៅហើយការព្យាបាលនោះនៅតែពុំទាន់ទទួលបានលទ្ធផលគួរជាទីសង្ឃឹមសោះ*"។

សាច់ញាតិកញ្ញា *ទូច ស៊ុននិច* បានឱ្យដឹងទៀតថាជិត៥ឆ្នាំកន្លងមកនេះ ការចំណាយលើថ្លៃព្យាបាលគឺអស់ទឹកប្រាក់ជិត៣០ម៉ឺនដុល្លារហើយ ដែលក្នុងថវិកាចំណាយនេះ ក៏បានមកពីការជួយឧបត្ថម្ភរបស់សប្បុរសជនបន្តិចបន្តួចដែរ។ តែក្រៅពីនេះ សុទ្ធតែជាប្រាក់ដែលបារបស់នាងបានលក់ដីប៉ុន្មានហិកតានៅខេត្តកំពង់ស្ពឺ និងផ្ទះមួយល្វែងក្នុងទីក្រុងភ្នំពេញ។

គេបានបញ្ជាក់បន្ថែមទៀតថា នៅសល់ផ្ទះមួយល្វែងចុងក្រោយនៅត្រង់ម្តុំផ្សារស៊ីឡឹបដែលដាក់ជួលឱ្យគេបាន១ខែ៤០០ដុល្លារនោះក៏បំរុងនឹងលក់ចេញដែរ ដើម្បីយកលុយទៅសង្គ្រោះអាយុជីវិតរបស់កញ្ញា *ទូច ស៊ុននិច*។

មជ្ឈដ្ឋានជាទូទៅបានរិះគន់ដល់អាជ្ញាធរនៃរដ្ឋាភិបាលលោក *ហ៊ុន សែន* ថា ដូចជាពុំមានសមត្ថភាពអ្វីទាល់តែសោះព្រោះរយៈពេលនៃការបាញ់ប្រហារនេះបានកន្លងទៅជិត៥ឆ្នាំហើយនៅតែរកមុខឃាតកមិនឃើញទៀតតើឱ្យប្រជាពលរដ្ឋសង្ឃឹមយ៉ាងដូចម្តេចបាន ?

គួររំលឹកថា ក្រោយពេលឃាតកបាញ់ប្រហារកញ្ញា *ទូច ស៊ុននិច* និងម្តាយរបស់នាងបានប៉ុន្មានថ្ងៃ អាជ្ញាធរមានសមត្ថកិច្ចបានគូរព្រាងនូវគំនូរមុខជនសង្ស័យដើម្បីស៊ើបអង្កេត និងស្វែងរកចាប់ខ្លួនយកមកផ្តន្ទាទោសតាមច្បាប់។

ប៉ុន្តែការស្វែងរក និងការប្រកាសផ្សាយដំណឹងនោះ ក៏ត្រូវចប់ទៅយ៉ាងស្ងៀមស្ងាត់រហូតមកដល់សព្វថ្ងៃនេះតែម្តងទៅ។ ឥឡូវចូលដល់រឿងឃាតកម្មលោក *ឃឹម សម្បូរណ៍* អ្នកនិពន្ធឱ្យកាសែតមនសិការខ្មែរ និងកូនប្រុសរបស់គាត់កំពុងតែចាប់ផ្តើមស៊ើបអង្កេតទៀតហើយ តែលទ្ធផលយ៉ាងណាៗនោះ សុំកុំឱ្យដូចករណីតារាចម្រៀង*ទូច ស៊ុននិច* ទៀតឱ្យសោះពោលគឺកុំឱ្យឃាតករស់នៅក្រៅសំណាញ់ច្បាប់យ៉ាងដូច្នេះវាជារឿងអយុត្តិធម៌ណាស់៕

**តមកពីទំព័រ២ គ**

រចនាសម្ព័ន្ធមនុស្សរបស់ខ្លួន ជាពិសេសពីមនុស្សឱកាសនិយមទាំងឡាយពីគណបក្សដទៃទៀតនោះ ។

លោកបណ្ឌិត *ឡៅ ម៉ុងហៃ* អ្នកស្រាវជ្រាវជាន់ខ្ពស់នៃគណៈកម្មាធិការសិទ្ធិមនុស្សអាស៊ីដែលមានមូលដ្ឋាននៅទីក្រុងហុងកុង បានអធិប្បាយពីលក្ខណៈនៃការបំប៉ោងចំនួនកៅអីរបស់រដ្ឋាភិបាលថ្មីថា "*នេះជាលក្ខណៈមួយនៃប្រទេសដែលអំណាចប្រមូលផ្តុំនៅលើមនុស្សតែម្នាក់* " ។

ដើម្បីជាការបញ្ជាក់បន្ថែមនោះលោកបណ្ឌិតបានអធិប្បាយទៅដល់របៀបរបបប្រហាក់ប្រហែលគ្នានៅប្រទេសស៊ីរីលង្កាក្នុងតំបន់អាស៊ីខាងត្បូង ។ នៅក្នុងប្រទេសនោះតាមសេចក្តីថ្លែងរបស់លោក *ឡៅ ម៉ុងហៃ* ថា ប្រធានាធិបតី ក៏ដូចជានាយករដ្ឋមន្ត្រី ម្នាក់ៗសុទ្ធតែបង្កើនចំនួនបុគ្គលិកទីប្រឹក្សារបស់ខ្លួនជាមធ្យោបាយមួយដើម្បីកុំឱ្យមានការច្រណែនគ្នា ឬប្រឆាំងនឹងគ្នាដែលនាំឱ្យមានការគំរាមដល់ស្ថេរភាពនយោបាយរបស់ពួកគេ ។

ជាការអធិប្បាយបន្តនោះ លោកបណ្ឌិត*ឡៅ ម៉ុងហៃ* បានលើកឡើងយកល្អគេគួរតែសង្កត់ទៅលើប្រសិទ្ធភាពការងារព្រោះបើមានមន្ត្រីណាម្នាក់ធ្វើការមានប្រសិទ្ធភាពខ្ពស់ហើយនោះវាមិនគួរចាំបាច់អ្វីទៅបំបែកការងារឱ្យមនុស្សដទៃទៀតធ្វើឱ្យបានច្រើនគ្នានោះឡើយ ។លោកបានប្រៀបធៀបដោយលើកយកនូវសុភាសិតខ្មែរអធិប្បាយអំពីរបស់ដែលហៅថា "*គ្នាច្រើនអន្សមខ្លោចគ្នាដូចស្រមោចអន្សមឆៅ* " ។

ការពិពណ៌នានេះមានលក្ខណៈជាការត្រឹមត្រូវ ដោយសារថាការបង្កើនចំនួនតំណែងកៅអីដើម្បីបែងចែកគ្នាជាការព្យាយាមលួងចិត្តមនុស្សឱកាសនិយមទាំងឡាយវានឹងបង្កើតជាទម្លាប់អាក្រក់ ហើយក៏ផ្តល់នូវបរិយាកាសឱ្យមានការរីករាលដាលនៃអំពើពុករលួយទាំងប្រសិទ្ធភាពការងារក៏នៅប្រទាញប្រទង់គ្នាមិនបានផលអ្វីជាដុំកំភួនដើម្បីផលប្រយោជន៍ជាតិ និងប្រជារាស្ត្រខ្មែរនោះទេ ។

លោកបានបន្តថ្លែងរិះគន់ថា តើការបង្កើនតំណែងឱ្យបានច្រើនដើម្បីបែងចែកទៅឱ្យគ្នីគ្នា ហើយបង្កើនបន្ទុកចំណាយថវិការដ្ឋនៅពេលដែលប្រទេសកម្ពុជាជាប្រទេសក្រីក្រ រស់ពឹងលើជំនួយបរទេស ទាំងអស់ហ្នឹងបណ្តាលមកពីពួកមន្ត្រីទាំងនោះមិនមានសមត្ថភាពអ្វីនឹងរកស៊ីចិញ្ចឹមខ្លួនឱ្យរស់ឬ បានជាចង់តែធ្វើការរដ្ឋនោះ ។

បញ្ជាក់បន្ថែមទៀតនោះ លោក *ឡៅ ម៉ុងហៃ* បានអធិប្បាយថា កម្ពុជាបច្ចុប្បន្នមានពលរដ្ឋ១ភាគ៣មានក្រពះប្រហោង ដោយខ្វះអាហារក្នុងពេលដែលមនុស្ស២ភាគ៣អាចបំពេញក្រពះបានគ្រប់គ្រាន់ ។ លោកបានលើកបំផុសនូវសំណួរឱ្យមានការពិចារណាថាតើមួយចំនួនដែលគេមានក្រពះពេញឆ្អែតទៅហើយ ហេតុអ្វីគេមិនគោរពសិទ្ធិពលរដ្ឋរបស់ខ្លួនដែលមានជីវភាពក្រីក្រខ្វះខាតមុខក្រោយនោះ ។ នៅកម្ពុជាពួកអ្នកមានក៏ដូចជាអ្នកមានអំណាចតែងតែមិនស្កប់ទៅដោយទ្រព្យសម្បត្តិនានាក្នុងការធ្វើសកម្មភាពរឹបអូសទ្រព្យសម្បត្តិរដ្ឋនិងរំលោភយកទ្រព្យសម្បត្តិរាស្ត្របង្កើតជាការជិះជាន់ផ្នែកសិទ្ធិមនុស្សយ៉ាងកំរោលទៅលើប្រជារាស្ត្រក្រីក្រដែលជាជនរួមជាតិរបស់ខ្លួននោះ ។

ពួកអ្នកសង្កេតការណ៍វាយតម្លៃថា ការបង្កើនចំនួនតំណែងកៅអីក្នុងរដ្ឋាភិបាលថ្មីនេះ គឺជាការធ្វើសកម្មភាពរបស់លោក *ហ៊ុន សែន* ត្បូកទៅលើលោក *ហ៊ុន សែន* ខ្លួនឯង ពីព្រោះកាលពីគ្រាមុនៗលោក *ហ៊ុន សែន* តែងតែលើកអំពីរបស់ដែលហៅថា ពួកមន្ត្រីជើងដប់ សំដៅដល់ពួកមន្ត្រីដែលចង់តែបានការងារក្នុងតំណែងនោះ ។ ហើយឥឡូវនេះអ្វីៗនៃការប្រព្រឹត្តជាក់ស្តែងរបស់លោក*ហ៊ុន សែន* មិនមែនជាការគិតគូរដល់ប្រយោជន៍ប្រជារាស្ត្រជាធំនោះទេ ប៉ុន្តែវាគ្រាន់តែជាការរក្សាអំណាចតំណែងទោះជា ត្រូវធ្វើអ្វីៗដូចជាការបង្កើនចំនួនមន្ត្រីឥតបានការដើម្បីជួយទប់ទ្រអំណាចរបស់ខ្លួនប៉ុណ្ណោះ ៕

**តមកពីទំព័រ១ ខ**

ដើម ។ ប៉ុន្តែនៅទីក្រុងភ្នំពេញវិញ ថ្នាក់ដឹកនាំគណបក្សប្រជាជន ( ស៊ីភីភី ) កំពុងតែបញ្ចេញចង្កូមចង់ប្លន់យកអាសនៈរបស់គណបក្សសម រង្ស៊ី ចំនួន២៦ និងអាសនៈរបស់គណបក្សសិទ្ធិមនុស្ស របស់លោក*កឹម សុខា* ចំនួន៣ដែរ ។

ការព្រមានជាចំហ ចង់បានអាសនៈ របស់គណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សពីសំណាក់មន្ត្រីស៊ីភីភី បើសិនជាអ្នកតំណាងរាស្ត្រ គណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស មិនចូលរួមប្រជុំ នៅថ្ងៃដំបូងដែលគ្រោងនឹងធ្វើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៨ នេះ វាដូចជា ពួកមន្ត្រីស៊ីភីភីទាំងអស់នោះចាត់ទុកថាខ្លួនគេគឺជាពួកលោភលន់ ណាស់ដែរ, ហើយពួកលោភលន់ ប្រភេទនេះ នឹងធ្វើឱ្យប្រទេសជាតិជួបនូវបញ្ហាធ្ងន់ធ្ងរណាស់ ពីព្រោះពួកគេ បានលួចឆន្ទៈប្រជាពលរដ្ឋ ដែលគាំទ្រគណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សជិត២លាននាក់ មិនអោយបោះឆ្នោតបានហើយ ចង់ប្លន់ឆន្ទៈប្រជាពលរដ្ឋខ្មែរដែលបានបោះឆ្នោតជូនអ្នកស្នេហាជាតិ បានចំនួន២៩អាសនៈទៀត ។

មតិនានានិយាយថា នៅប្រទេសកម្ពុជាសព្វថ្ងៃ មិនធម្មតាទេ ពិសេសរយៈពេលជាងមួយខែចុងក្រោយនេះ ដែលក្រុមចោរឈ្លានពានសៀម ឈ្លានពានទឹកដីខ្មែរ យ៉ាងងើលនៅតាមព្រំដែនហើយ មានពួកលោភរបស់គណបក្សប្រជាជនកម្ពុជា ចង់ប្លន់យកអាសនៈពីគណបក្សប្រឆាំង ចំនួន២៩ធ្វើជាកម្មសិទ្ធិទៀតដោយសារតែគណបក្សប្រឆាំង មិនព្រមចូលរួមប្រជុំ ជាមួយអ្នកលួចបន្លំសន្លឹកឆ្នោត និងអ្នកដែលហាមមិនអោយប្រជាពលរដ្ឋ ជាង២លាននាក់ ទៅបោះឆ្នោតបាន កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០០៨ ។

ទោះយ៉ាងណា លោក*សម រង្ស៊ី* និងលោក*កឹម សុខា* ដែលតាំងចិត្ត និងប្តេជ្ញាតស៊ូនាំយកភស្តុតាង ឯកសារ ស្តីពីភាពមិនប្រក្រតី នៅក្នុងការបោះឆ្នោតនេះ ទៅប្តឹងអង្គការសហប្រជាជាតិ និងសហគមន៍អឺរ៉ុប នៅខែក្រោយហើយ ដើម្បីឱ្យពិភពលោកស្គាល់ច្បាស់ មុខមាត់ពួកលោភលន់ លួចឆន្ទៈរបស់ប្រជាពលរដ្ឋខ្មែរ និងអ្នកដែលលួចបន្លំសន្លឹកឆ្នោត ជាពិសេសអ្នកដែលហាមខ្មែរជាង ១លាននាក់ មិនឱ្យបោះឆ្នោត និងអនុញ្ញាត ឱ្យយួនរាប់សែននាក់បោះឆ្នោត សំរេចនូវជោគវាសនាខ្មែរបាន ។

លោក*ហ៊ុន សែន* អនុប្រធានគណបក្សប្រជាជន និងលោក*ជាម យៀប* មន្ត្រីជាន់ខ្ពស់គណបក្សប្រជាជន បានព្រមានថា នឹងយកអាសនៈរបស់គណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស ធ្វើជាកម្មសិទ្ធិរបស់ខ្លួនបើសិនជាអ្នកតំណាងរាស្ត្រទាំង២៩ របស់គណបក្សទាំងពីរ មិនព្រមចូលរួមប្រជុំនៅថ្ងៃដំបូង នៅថ្ងៃទី២៤ ខែកញ្ញា ២០០៨ទេនោះ ។

អ្នកច្បាប់ម្នាក់ បាននិយាយ គណបក្សប្រជាជនបានព្រមានដូចគ្នានេះម្តងហើយ កាលពីឆ្នាំ ២០០៣ ក្រោយការបោះឆ្នោតមិនប្រក្រតីនោះថាបើសមាជិកសភា គណបក្សសម រង្ស៊ី និង គណបក្សហ៊្វុនស៊ិនប៉ិច សរុបចំនួន៥០នាក់( ហ៊្វុនស៊ិនប៉ិច២៦ និងសមរង្ស៊ី២៤) មិនព្រមចូលរួមប្រជុំ នៅថ្ងៃដំបូងទេ គេ ( ស៊ីភីភី ) នឹងយកអាសនៈ ទាំង៥០នោះដែរ ។ ប៉ុន្តែសមាជិកសភាគណបក្សសម រង្ស៊ី និង ហ៊្វុនស៊ិនប៉ិច ទាំង៥០រូបនោះ មិនព្រមចូលរួមប្រជុំទេ,ហើយ ស៊ីភីភី ក៏មិនហ៊ានប្លន់យកកៅអីអ្នកតំណាងរាស្ត្រ ទាំង៥០ នោះដែរ ដោយជាប់គាំងនយោបាយ ពន្យារពេលជិតមួយឆ្នាំ ក្រោយការបោះឆ្នោតទើបដោះស្រាយភាពជាប់គាំងបាន គឺ ទ្រង់*រណឫទ្ធិ* លក់ឧត្តមគតិនិងទទួលបានលាភសក្ការៈ ពីប្រមុខរដ្ឋាភិបាល*ហ៊ុន សែន* សុខចិត្តធ្វើរដ្ឋាភិបាលចម្រុះជាមួយគណបក្សប្រជាជន ។

អ្នកច្បាប់ បាននិយាយថា គណបក្សប្រជាជន ពិសេសប្រមុខរដ្ឋាភិបាលចាំផ្ទះ*ហ៊ុន សែន* និងលោក*ជាម យៀប* មន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនមិនអាចប្លន់យកអាសនៈសមាជិកសភាគណបក្សសម រង្ស៊ី និង គណបក្សសិទ្ធិមនុស្ស ទាំង២៩ អាសនៈធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនបានទេ, ហើយបើពួកគេហ៊ានធ្វើដូច្នេះមែន មានន័យថានៅកម្ពុជាសព្វថ្ងៃ ចោរសៀម និង ពួកលោភលន់ស៊ីភីភី អុកឡុកពេញអាណាចក្រខ្មែរហើយ ។

ទោះយ៉ាងណាបណ្តាញផ្សព្វផ្សាយរបស់គណបក្សប្រជាជន បានបង្ហាញពីភាពស្លន់ស្លោ នឹងព័ត៌មានដែលថាគណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស របស់លោក*កឹម សុខា* នាំយកឯកសារ ភស្តុតាង នៃការលួចបន្លំសន្លឹកឆ្នោតទៅប្តឹងតំណាងអង្គការសហប្រជាជាតិ និង សហគមន៍អឺរ៉ុប នៅប៉ុន្មានថ្ងៃមុខនេះហើយ ។ ដូច្នេះហើយ បានជាក្រុមលោភលន់ ដែលគ្រោងប្លន់យកអាសនៈ របស់គណបក្សសមរង្ស៊ីនិងគណបក្សសិទ្ធិមនុស្សនោះខ្លាចហើយពួកគេខំស្រែកនិងធ្វើអត្ថាធិប្បាយតាមវិទ្យុ និងទូរទស្សន៍ប៉ុន្មានថ្ងៃនេះគួរឱ្យស្អប់ខ្ពើមបំផុត ៕

**តមកពីទំព័រ៤ ស**

*សាមាក់ ស៊ុនដារ៉ាវេត* បានព្រមានអំពីការធ្លាក់បាក់មុខមាត់នៃការបាក់បែកប្រទេសសៀមបច្ចុប្បន្ននិងបង្កើតភាពអាម៉ាស់ចំពោះប្រទេសសៀមនៅលើឆាកអន្តរជាតិ ។

នេះក៏ជាលេសសមទំនងមួយដើម្បីឱ្យរដ្ឋាភិបាលសៀមគេចវេសពីការចូលតុចរចាទ្វេភាគីខ្មែរសៀមដែលបានគ្រោងរៀបចំឡើងនៅក្រុងសៀមរាបកាលពីថ្ងៃទី២៩ខែសីហាហើយត្រូវលុបចោលទៅវិញនោះ ។ ចំពោះមុខស្ថានភាពបែបនេះរដ្ឋាភិបាលកម្ពុជា ជាពិសេសលោក *ហ៊ុន សែន* ផ្ទាល់ដូចជាមានអារម្មណ៍មិនស្រួលចិត្តគិតអំពីដំណើរនៃការរងការរិះគន់ខ្លាំងឡើងៗថា ធ្វើអ្វីតាមតែសៀមអូសទាញ បង្វែង ពង្វក់រឿងសៀមចូលឈ្លានពានកាន់កាប់ដីខ្មែរតំបន់ព្រំដែននោះ ។

លោក *ហ៊ុន សែន* បានចាត់បញ្ជាឱ្យប្រមុខការទូតកម្ពុជា *ហោ ណាំហុង* ស្វះស្វែងជំរុញឱ្យបានកាន់តែឆាប់រកការជួបចរចាទ្វេភាគីជាមួយមេដឹកនាំសៀមឡើងវិញរឿងនៃការប្រឈមមុខដាក់គ្នាផ្នែកយោធានៅតាមបណ្តោយព្រំដែននោះ ។

បញ្ហាអស់នេះបង្កើតជាសេចក្តីសង្ស័យដោយមូលហេតុសមទំនងថា ទំនងជាមេដឹកនាំកម្ពុជា ពោលគឺលោក *ហ៊ុន សែន* គណបក្សប្រជាជនអាចមានកិច្ចសន្យាសម្ងាត់នៃផលប្រយោជន៍រួមគ្នាជាមួយមេដឹកនាំសៀម ជាពិសេស *ថាក់ ស៊ីន ស៊ីណាវ៉ាត្រា* ដែលនៅតែត្រូវមជ្ឈដ្ឋានអ្នកនយោបាយ និងប្រជារាស្ត្រចាត់ទុកថា ជាអ្នកនៅពីក្រោយខ្នងនាយករដ្ឋមន្ត្រីសៀមបច្ចុប្បន្ននោះ ។

ចម្លើយរបស់មជ្ឈដ្ឋាននានាទាំងប្រជារាស្ត្រខ្មែរមានហេតុផលនោះ ពីព្រោះថា បើពុំមានកិច្ចការចាំបាច់អ្វីនឹងត្រូវគិតខ្វល់បែបនេះទេ ហេតុអ្វីក៏ចាំបាច់នាយករដ្ឋមន្ត្រីខ្មែរ *ហ៊ុន សែន* ស្វះស្វែងខ្នះខ្នែងប្រើរដ្ឋមន្ត្រីការបរទេស *ហោ ណាំហុង* ឱ្យតាមទាក់ទងរកការកំណត់ពេលជួបជាមួយមេដឹកនាំសៀមដើម្បីនិយាយគ្នាបន្តទៀតរឿងជម្លោះតាមព្រំដែន ។ មជ្ឈដ្ឋានអ្នកសង្កេតការណ៍ ទាំងមន្ត្រីជំនាញទូទៅមើលឃើញថា ឥរិយាបថរបស់រដ្ឋាភិបាលគណបក្សប្រជាជន *ហ៊ុន សែន* ធ្វើបែបនេះបង្ហាញនូវភាពទន់ខ្សោយ និងធ្វើឱ្យប្រទេសកម្ពុជាអាម៉ាស់នៅចំពោះមុខនយោបាយដើរតោងកន្ទុយក្បិនសៀមរហូតនិងធ្វើឱ្យកម្ពុជាចាញ់ប្រៀបសៀមនៅតុចរចាក៏ដូចជានៅទីប្រឈមមុខដាក់គ្នានោះ ។

លោក *ស៊ាន ប៉េងសែ* បាននិយាយថា ការចាំបាច់ដែលកម្ពុជាត្រូវធ្វើ មិនមែនការត្រូវទៅតាមអង្វរសុំឱ្យសៀមចូលតុចរចានោះទេ ពីព្រោះកម្ពុជាមានមូលដ្ឋានច្បាប់សព្វបែបយ៉ាងក្នុងប្រៀបយកឈ្នះលើសៀមដោយសន្តិវិធីតាមផ្លូវច្បាប់ដូចជាតាមរយៈបណ្តឹងទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនោះ ។

តាមការវិនិច្ឆ័យរបស់លោក *ស៊ាន ប៉េងសែ* ប្រធានគណៈកម្មការព្រំដែនកម្ពុជាដែលមានមូលដ្ឋាននៅទីក្រុងប៉ារីសប្រទេសបារាំង និងធ្វើសកម្មភាពដើម្បីបុព្វហេតុទឹកដីកម្ពុជាតាមរយៈការងារនៅបណ្តាប្រទេសទាំងឡាយនោះថា រដ្ឋាភិបាល *ហ៊ុន សែន* បានដើរនយោបាយចាញ់បោកសៀម ដូចជាសុខៗនៅឯជំនួបក្រុងហួរហ៊ីន ថ្ងៃទី១៨-១៩ សីហា រដ្ឋមន្ត្រីការបរទេស *ហោ ណាំហុង* បែរជាប្រកាសយល់ព្រមធ្វើតាមការចរចារបស់សៀមទាំងសៀមមិនបានសុំ គឺការដកបណ្តឹងពីក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិផង និងប្រកាសដកទ័ពជាឯកតោភាគីពីដីខ្មែរដែលសៀមចូលឈ្លានពាននោះផង ។

លោក *ស៊ាន ប៉េងសែ* បានអធិប្បាយថា កម្ពុជាមានគ្រប់លក្ខណៈសម្បត្តិ ដើម្បីតទល់តាមសន្តិវិធីផ្លូវច្បាប់លើសៀមនៅឯវេទិកាពហុភាគីដើម្បីជាការធានាថា អ្វីៗនឹងចប់ស្រេចបាច់ ជាជាងការនៅតែធ្វើតាមការចង់បានរបស់សៀមជួបគ្នាតែត្រឹមទ្វេភាគី ហើយមិនហ៊ានយករឿងនេះទៅប្តឹងដល់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិឱ្យរកដំណោះស្រាយឱ្យនោះ ។

លោកបានបន្ទោសលើកំហុសនយោបាយដ៏ធំរបស់លោក*ហ៊ុន សែន*ក្នុងការព្រមចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាជាថ្មីជាមួយសៀមក្នុងឆ្នាំ២០០០ ២០០៣ ។ល ។ ហើយបើយោងលើឯកសារថ្មីផ្ទុយទាំងស្រុងនឹងឯកសារជាមូលដ្ឋានផ្លូវច្បាប់អន្តរជាតិដែលកម្ពុជាមានស្រាប់នោះ អនុស្សារណៈថ្មីដែល *ហ៊ុន សែន*បាននិយាយជាមួយសៀម ធ្វើឱ្យសៀមបង្កើតជាលេសបង្ករបញ្ហាថ្មីៗឱ្យកម្ពុជា ដូចជាការលើកទាហានឱ្យចូលកាន់កាប់ដីខ្មែរជាដើមនោះ ។

លោក *ស៊ាន ប៉េងសែ* បានពន្យល់ថា អនុស្សារណៈនេះខុសច្បាប់ ហើយអាចឱ្យសៀមប្រើប្រាស់ដើម្បីព្យាយាមលុបចោលនូវឯកសារច្បាប់អន្តរជាតិទាំងនោះ ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ សកម្មជនការពារព្រំដែនរូបនេះបានអត្ថាធិប្បាយថា អនុសញ្ញាបារាំង-សៀមឆ្នាំ ១៩០៤ និងសន្ធិសញ្ញាបារាំង-សៀមឆ្នាំ១៩០៧ ដែលសៀមនិងបារាំងចុះហត្ថលេខារវាងគ្នាស្តីពីបញ្ហាព្រំដែនខ្មែរសៀមព្រមទាំងសាលក្រមតុលាការអន្តរជាតិក្រុងឡាអេឆ្នាំ១៩៦២ សម្រេចបញ្ជាក់ច្បាស់អំពីប្រាសាទព្រះវិហារ និងដីតំបន់ជុំវិញជាសម្បត្តិរបស់ប្រទេសកម្ពុជានោះ គឺជាមូលដ្ឋានសម្រាប់ឱ្យកម្ពុជាយកឈ្នះលើសៀម នៅវេទិការអន្តរជាតិនានា ទាំងនៅលើឆាកអន្តរជាតិជាដើម ។

លោកក៏បាននិយាយផងដែរថា ដោយសារតុលាការអន្តរជាតិនៅក្នុងបន្ទុកឬក្រោមឱវាទរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនោះ ដូច្នេះអ្វីៗដែលកម្ពុជាត្រូវធ្វើដំបូងដើម្បីកុំឱ្យខាតបង់ពេលវេលា និងកុំឱ្យចាញ់ប្រៀបក្នុងដំណោះស្រាយបញ្ចប់បញ្ហាសៀមឈ្លានពាននោះ មានតែរដ្ឋាភិបាលកម្ពុជាប្រញាប់ដាក់បណ្តឹងទៅក្រុមប្រឹក្សាសន្តិសុខភ្លាមៗ ។

ការដែល *ហ៊ុន សែន* ប្រាប់ឱ្យ *ហោ ណាំហុង* តាមទាក់ទងសុំបន្តការចរចាជាថ្មីជាមួយមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលសៀមជុំវិញបញ្ហានៃជម្លោះទឹកដីព្រំដែននោះទាំងនេះដូចជាប្រាប់ឱ្យដឹងថា *ហ៊ុន សែន* កំពុងមានកង្វល់យ៉ាងខ្លាំងប្រឈមនឹងការថ្កោលទោសរបស់ប្រជារាស្ត្រខ្មែរដែលមើលឃើញថា រដ្ឋាភិបាលគណបក្សប្រជាជន *ហ៊ុន សែន* ធ្វើនយោបាយចាញ់ប្រៀបសៀម ហើយអាចបង្កើតជាបញ្ហាគ្រោះបាត់បង់ទឹកដីខ្មែរនៅតំបន់អស់ទាំងនោះ ៕

**សេវាទទួលទិញសម្ភារៈចាស់ៗ**

មានទទួលទិញ : ផ្ទះឈើ ផ្ទះថ្ម និងសំណង់អគារចាស់ៗតូច-ធំ គ្រប់ប្រភេទដែលត្រូវការរុះរើ ឬវាយចោល និង សម្ភារៈអេតចាយជាច្រើនមុខទៀតដូចជា : ដែក ស្ពាន់ អាលុយមីញ៉ូម ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនភ្លើង អាគុយ ម៉ូទ័រ ។ល ។

-មានសេវាចុះទិញតាមខេត្ត-ក្រុងទូទាំងប្រទេសកម្ពុជា

-មានទទួលទិញក្នុងតម្លៃសមរម្យ

-ចំពោះអ្នកដែលផ្តល់ព័ត៌មានក្នុងការទិញលក់នេះ ក្រុមហ៊ុននឹងផ្តល់កម្រៃជើងសារបន្ថែម

ទំនាក់ទំនងទូរស័ព្ទលេខ : **017 606 125**

**ក្រុមហ៊ុនភាពយន្តជនបទ**

**មានទទួលបញ្ចាំង**
**ខ្សែភាពយន្តខ្នាតធំ**
**ក្នុងពិធីផ្សេងៗ**
**មានពន្លឺច្បាស់**
**ទំនាក់ទំនងតាមទូរស័ព្ទ**
**012 66 44 67**
**015 66 44 67**

ខ្មែរម្ចាស់ស្រុក
Khmer Machas Srok News

ការិយាល័យនិពន្ធ
Tel : 012 969 832 , 012 850 690
Fax : 023 987 411
E-mail: kmsnews@gmail.com
www.kmsblog.wordpress.com
ផ្នែកផ្សាយពាណិជ្ជកម្ម
Tel: 012 850 690 , 017 360 678, 015 645 170

តមកពីទំព័រ១ ម

រដ្ឋខ្មែរដែលខកខានមិនបានបោះឆ្នោតកាលពីថ្ងៃទី២៧ខែកក្កដាឆ្នាំ២០០៨។

គួរបញ្ជាក់ថា គណបក្សសមរង្ស៊ីនិងគណបក្សសិទ្ធិមនុស្ស បានប្តឹងទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងក្រុមប្រឹក្សាធម្មនុញ្ញបដិសេធលទ្ធផលនៃការបោះឆ្នោត និងទាមទារឱ្យមានការបោះឆ្នោតឡើងវិញនៅទូទាំងប្រទេស ដោយសារតែមានភាពមិនប្រក្រតីនៃបញ្ជីឈ្មោះអ្នកបោះឆ្នោត និងការរាប់សន្លឹកឆ្នោតដែលធ្វើឱ្យអ្នកមានសិទ្ធិបោះឆ្នោតប្រមាណ ១លាននាក់ត្រូវបាត់បង់សិទ្ធិបោះឆ្នោតដោយគ្មានមូលហេតុច្បាស់លាស់ទាល់តែសោះ។

មុននេះបន្តិចគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងក្រុមប្រឹក្សាធម្មនុញ្ញបានច្រានចោលនូវពាក្យបណ្តឹងស្តីពីភាពមិនប្រក្រតីទាំងអស់ហើយ ថែមទាំងប្រកាសបិទផ្លូវមិនឱ្យគណបក្សប្រឆាំងទាំងពីរធ្វើការតវ៉ាទៀតផង។

ទោះជាដូច្នេះក៏ដោយ ក៏លោក សម រង្ស៊ី ប្រធានគណបក្សសមរង្ស៊ីបានមានប្រសាសន៍ប្រាប់បណ្តាញព័ត៌មានថា "គណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សមានឯកសារភស្តុតាង និងសាក្សីដែលសុទ្ធតែជាមូលដ្ឋានច្បាប់យ៉ាងរឹងមាំសម្រាប់ធ្វើការតវ៉ាអំពីភាពមិនប្រក្រតីនៃការបោះឆ្នោត ពិសេសគឺសុំឱ្យសហគមន៍អន្តរជាតិកុំទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតដ៏អយុត្តិធម៌នេះផងដែរ"។

លោក សម រង្ស៊ី បានមានប្រសាសន៍បន្តទៀតថា "សំខាន់បំផុតគឺសុំឱ្យសហគមន៍អន្តរជាតិកុំមានទំនាក់ទំនងអ្វីជាមួយរដ្ឋាភិបាលដែលកើតចេញពីការបោះឆ្នោតមិនត្រឹមត្រូវ និងមិនយុត្តិធម៌"។

មេដឹកនាំគណបក្សជំទាស់ដ៏ធំបំផុតនៅក្នុងប្រទេសកម្ពុជារូបនេះបានអត្ថាធិប្បាយយ៉ាងម៉ឺងម៉ាត់តាមផ្លូវច្បាប់ថា "យើងនឹងរកមេធាវីអន្តរជាតិដូចជាមេធាវីនៅសហរដ្ឋអាមេរិក, មេធាវីនៅទ្វីបអឺរ៉ុបដើម្បីប្តឹងចំពោះការបោះឆ្នោតនេះ ហើយទាមទារឱ្យរដ្ឋាភិបាលនៃប្រទេសនានាដែលធ្លាប់មានទំនាក់ទំនងជាមួយរដ្ឋាភិបាលទីក្រុងភ្នំពេញ គឺត្រូវតែពិនិត្យឡើងវិញសម្រាប់អាណត្តិទី៤នេះ ព្រោះរដ្ឋាភិបាលអាណត្តិទី៤ហ្នឹងកើតចេញពីសភាមួយមិនត្រឹមត្រូវ ។ហើយសភាមិនត្រឹមត្រូវនេះ ក៏កើតចេញមកពីការបោះឆ្នោតមិនត្រឹមត្រូវដែរ"។

លោកបានបន្តទៀតថា "អញ្ចឹងទេ គឺយើងសុំកុំឱ្យមានទំនាក់ទំនងជាមួយរដ្ឋាភិបាលដែលកើតចេញមកពីសភាមិនត្រឹមត្រូវនេះឱ្យសោះ"។

ជាមួយគ្នានេះដែរ លោក កឹមសុខា ប្រធានគណបក្សសិទ្ធិមនុស្សក៏បានមានប្រសាសន៍ផងដែរថា "យើងនឹងបង្ហាញប្រាប់សហគមន៍អន្តរជាតិអំពីការស្លាប់នៃដំណើរប្រជាធិបតេយ្យនៅកម្ពុជាប្រសិនបើសហគមន៍អន្តរជាតិនៅតែមិនព្រមជួយធ្វើអន្តរាគមន៍ដោះស្រាយភាពមិនប្រក្រតី នៃការបោះឆ្នោតកាលពីខែកក្កដានោះទេ"។

លោកកឹម សុខាបានសង្កត់ធ្ងន់ថា "គណបក្សប្រឆាំងបានប្តឹងផ្តល់ទៅស្ថាប័នកំពូលហើយ នៅតែរកយុត្តិធម៌មិនឃើញ គឺយើងត្រូវតែប្តឹងទៅរកភាគីទី៣ដើម្បីជាអាជ្ញាកណ្តាល ។មានន័យថា យើងនឹងបន្តប្តឹងទៅសហគមន៍អន្តរជាតិដែលផ្តើមចេញពីបណ្តាប្រទេសហត្ថលេខីនៃកិច្ចព្រមព្រៀងក្រុងប៉ារីស, យើងប្តឹងទៅសហគមន៍អឺរ៉ុប, យើងប្តឹងទៅអង្គការសហប្រជាជាតិនិងប្តឹងទៅសហរដ្ឋអាមេរិកទៀត"។

ប្រធានគណបក្សសិទ្ធិមនុស្សរូបនេះបានអះអាងថា "គណបក្សប្រឆាំងទាំងពីរដែលចេញទៅតវ៉ាដល់អន្តរជាតិដើម្បីរកការជួយអន្តរាគមន៍ពីសហគមន៍អន្តរជាតិ និងជាយុទ្ធសាស្ត្រមួយដ៏សំខាន់បំផុតសំដៅធ្វើយ៉ាងណាឱ្យការបោះឆ្នោតនេះមានភាពយុត្តិធម៌។ ហើយនឹងបង្ហាញឱ្យឃើញកាន់តែច្បាស់ថែមទៀតថា ដំណើរការប្រជាធិបតេយ្យនៅកម្ពុជានឹងត្រូវស្លាប់យ៉ាងវេទនា ប្រសិនបើសហគមន៍អន្តរជាតិមិនបានដោះស្រាយបញ្ហាបោះឆ្នោតនៅឆ្នាំ២០០៨នេះទេ"។

ប្រជាពលរដ្ឋខ្មែរជាទូទៅមានជំនឿថា សហគមន៍អន្តរជាតិក៏ដូចជាអង្គការសហប្រជាជាតិមិនទុកឱ្យកម្ពុជាទទួលរងគ្រោះសាជាថ្មីទៀត ដោយសារការក្តោបក្តាប់អំណាចរបស់គណបក្សប្រជាជននោះទេ។

ទន្ទឹមនឹងសភាពការណ៍ជំទាស់ប្រឆាំងនឹងលទ្ធផលបែកធ្លាយទៅដល់សហគមន៍អន្តរជាតិនេះក្រុមអ្នកសង្កេតការណ៍គ្រប់មជ្ឈដ្ឋានបានមើលឃើញថា សូម្បីតែផ្ទៃក្នុងគណបក្សប្រជាជនក៏កំពុងប្រជែងគ្នាយ៉ាងពុះកញ្ជ្រោលដែរ ទើបមានការទម្លាយចេញនូវការបោះឆ្នោតជាកញ្ចប់សម្រាប់រដ្ឋសភា និងរដ្ឋាភិបាលអាណត្តិទី៤នេះទៀតនោះ។

គួររំលឹកថា កាលពីថ្ងៃអាទិត្យទី២៤ ខែសីហាកន្លងទៅនេះនៅឯសន្និសីទកាសែតមួយលោក ខៀវ កាញារីទ្ធ អ្នកនាំពាក្យគណបក្សប្រជាជន និងជារដ្ឋមន្ត្រីក្រសួងព័ត៌មាន បាននិយាយថា នៅពេលបង្កើតសភាជាតិអាណត្តិទី៤ជាផ្លូវការនៅថ្ងៃទី២៤ កញ្ញា ក៏នឹងមានការបោះឆ្នោតជាកញ្ចប់តែងតាំងថ្នាក់ដឹកនាំជាប្រធាន និងអនុប្រធានទាំងពីរ នៃសភាជាតិ។ គាត់បាននិយាយថា នៅពេលនោះក៏នឹងមានការបោះឆ្នោតកញ្ចប់ឱ្យមានការទទួលស្គាល់នាយករដ្ឋមន្ត្រីផងដែរមុននឹងមានការបង្កើតសមាសភាពរដ្ឋាភិបាលក្រោយមកទៀត។

ការថ្លែងបែបនេះរបស់អ្នកនាំពាក្យរដ្ឋាភិបាល ហ៊ុន សែន គឺជាបុព្វបទនាំឱ្យមានសេចក្តីមន្ទិលសង្ស័យថា ផ្ទៃក្នុងគណបក្សកាន់អំណាចពិតមែនតែបានលួចបន្លំសន្លឹកឆ្នោតរហូតបានអាសនៈសភារហូតដល់៩០ក៏ដោយ ក៏កំពុងតែមានការប្រទាញប្រទង់គ្នារឿងតំណែងនៅក្នុងរដ្ឋាភិបាលនោះហើយ។

ហ៊ុន សែន ក៏ត្រូវគេជឿថា នៅតែមិនមានសេចក្តីទុកចិត្ត ដូចដែលខ្លួនធ្លាប់បានឆ្លងកាត់ ហើយកើតមានជាការប្រជែងដណ្តើមអំណាចផ្ទៃក្នុងកាលពីអតីតកាលដែរនោះ។ លោក ខៀវ កាញារីទ្ធ បានពន្យល់ថា ការបោះឆ្នោតកញ្ចប់នោះដើម្បីជាការងាយស្រួលក្នុងការធ្វើឱ្យរួចស្រេចបាច់ជាមួយគ្នាពេលតែងតាំងថ្នាក់ដឹកនាំសភាជាតិ និងនាយករដ្ឋមន្ត្រីនោះ។

ប៉ុន្តែការបកស្រាយរបស់ ខៀវ កាញារីទ្ធបង្កើតជាសេចក្តីសង្ស័យរបស់មជ្ឈដ្ឋានទូទៅទៅវិញទេថា ហ៊ុន សែន ទំនងជាកំពុងទទួលរងគំនាបសង្កត់ផ្ទៃក្នុងរឿងគាត់នេះហួងហែងធ្វើជាមេចំណែកអំណាចក្នុងរដ្ឋាភិបាលនេះ ដូច្នេះក៏ចេះតែមិនទុកចិត្តផ្ទៃក្នុងខ្លួនឯងរឿងតំណែងជានាយករដ្ឋមន្ត្រីនេះ។

ទំនងជាដឹងអំពីភាពមិនងាយស្រួលជាពិសេសការដែលមានសម្ពាធពីខាងខ្សែប្រធានបក្ស ជា ស៊ីម ចង់បានតំណែងធំដុំអ្វីខ្លះនៅក្នុងរដ្ឋាភិបាលអាណត្តិទី៤ច្រើនជាងកាលចំណែកដែលបានក្នុងអាណត្តិទី៣នោះហើយ បានជាសម្ពាធនេះធ្វើឱ្យលោក ហ៊ុន សែន មានកង្វល់រហូតដល់អ្នកនាំពាក្យរបស់គាត់ចេញនិយាយថា ចង់ឱ្យមានការបោះឆ្នោតកញ្ចប់ជ្រើសតាំងនាយករដ្ឋមន្ត្រីតំណាលគ្នានឹងការតែងតាំងប្រធាន និងអនុប្រធាននៃសភាជាតិនោះ។

គេនៅចាំបានថាកាលពេលបង្កើតរដ្ឋាភិបាលអាណត្តិទី៣កន្លងទៅនោះក៏មានការប្រកួតប្រជែងដណ្តើមអំណាចផ្ទៃក្នុងនៃគណបក្សប្រជាជនរវាងខ្សែលោក ហ៊ុន សែន អនុប្រធានបក្សម្ខាងនិងខ្សែលោកជា ស៊ីម ប្រធានបក្សនេះម្ខាងទៀត។ ការប្រកួតប្រជែងនោះក៏ត្រូវបានគេដឹងដោយការលេចធ្លាយព័ត៌មានដល់ពួកអ្នកការទូតត្រូវដកស្រង់ដោយកាសែតបរទេសចុះផ្សាយ។

កាលនោះលោកហ៊ុន សែន ត្រូវបានគេដឹងថា បានធ្វើការកោះប្រជុំថ្នាក់ដឹកនាំជាន់ខ្ពស់គណបក្សប្រជាជនដោយបិទទ្វារ និងមិនមានការចូលរួមរបស់លោកជា ស៊ីមប្រធានគណបក្សប្រជាជននោះទេ។

ពួកអ្នកការទូតក៏ត្រូវបានដកស្រង់សម្តីចុះផ្សាយដោយសារព័ត៌មានបរទេសថា មានការប្រកួតប្រជែងគ្នារវាងខ្សែលោក ជា ស៊ីម និងខ្សែលោក ហ៊ុន សែន រឿងដណ្តើមតំណែងក្រសួងនេះក្រសួងនោះរវាងគ្នា។ ហើយលោកជា ស៊ីម កាលនោះបានទាមទារឱ្យមានការកាត់បន្ថយអំណាចខ្លះពីលោក សុខ អាន ខ្សែខាងលោក ហ៊ុន សែន ក៏ដូចជាឱ្យមានការប្រគល់តំណែងរដ្ឋមន្ត្រីក្រសួងកសិកម្ម ក្រសួងធនធានទឹក និងក្រសួងពាណិជ្ជកម្មពីខាងខ្សែលោក ហ៊ុន សែន ទៅឱ្យខាងខ្សែលោក ជា ស៊ីម។

ប៉ុន្តែការប្រកួតប្រជែងក្នុងជម្លោះដណ្តើមអំណាចផ្ទៃក្នុងនោះបានបែកធ្លាយជាសាធារណៈ ដូចដែលគេដឹងបានដោយកងកម្លាំងអង្គរក្សរបស់លោក ហ៊ុន សែន រួមជាមួយនឹងកងកម្លាំងប៉ូលិសនៅក្រោមបញ្ជារបស់លោក ហុក ឡងឌី ជាដន្លងរបស់លោក ហ៊ុន សែន បានហ៊ុំព័ទ្ធផ្ទះលោក ជា ស៊ីម ក៏ដូចជាផ្ទះលោក កែ គឹមយ៉ាន ដែលជាខ្សែខាងលោក ជា ស៊ីម នោះ ហើយក៏មានការនាំខ្លួនលោក ជា ស៊ីម យកទៅក្រុងបាងកកជាច្រើនសប្តាហ៍។គេបានពិពណ៌នាថា ក្នុងពេលដណ្តើមអំណាចផ្ទៃក្នុងនោះ លោក ហ៊ុន សែន បានឈ្នះលើខ្សែលោក ជា ស៊ីម ។ ហើយពិតមែនតែអំណាចត្រូវបានបែងចែកស្រេចបាច់ដោយខាងលោក ហ៊ុន សែន ប្រមូលបានស្ទើរតែទាំងមូលមកឱ្យបក្ខពួករបស់គាត់ក៏ដោយ ក៏ខាងលោក ជា ស៊ីម នៅតែត្រូវគេដឹងថាមិនសប្បាយចិត្តនឹងរបៀបបែងចែកអំណាចកាលនោះឡើយ។

រឿងបែងចែកអំណាចគ្នាក្នុងជួររដ្ឋាភិបាល សូម្បីតែក្នុងផ្ទៃគណបក្សប្រជាជននោះ ក៏នៅតែមានបញ្ហារការកូសមកដល់ពេលនេះ នៅពេលដែលការបង្កើតរដ្ឋាភិបាលនៅមិនទាន់ចេញជារូបរាងនៅឡើយនិងក្នុងពេលដែលគណបក្សប្រឆាំងដឹកនាំដោយគណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សបានចេញមុខធ្វើការប្រឆាំងតវ៉ានឹងលទ្ធផលនៃការបោះឆ្នោតប្រកបដោយការលួចបន្លំបោកប្រាស់ប្រជារាស្ត្រនោះ។

គេជឿថា បើសិនជាសហគមន៍អន្តរជាតិមិនបណ្តោយឱ្យលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាស្លាប់ទៅវិញនោះទេ គឺរដ្ឋាភិបាលអាណត្តិទី៤ ដែលដឹកនាំដោយលោក ហ៊ុន សែន មិនអាចញាស់ចេញពីសំបកខ្មៅងងឹតនេះបានឡើយ៕

តមកពីទំព័រ១ ស

លើកក្រោយនោះ ស្រាប់តែ ហ៊ុន សែន នៅថ្ងៃនោះបានធ្វើការប្រជុំគណៈរដ្ឋមន្ត្រី ហើយនិយាយដាស់តឿន ហោ ណាំហុង តាមទាក់ទងសុំបន្តការចរចាគ្នាជាមួយសៀមទៀត។ តើអ្វីជាប្រភពដើមនៃកម្លាំងរុញឱ្យមានការតាមរបៀបអង្វរសៀមឱ្យចូលតុចរចា ដោយដឹងសៀមបានប្រើលេសអំពីភាពវឹកវរនយោបាយនៅក្រុងបាងកក ដើម្បីលុបចោលគម្រោងនៃការចរចានោះ ?

នៅទីក្រុងបាងកក នាយករដ្ឋមន្ត្រីសៀម សាម៉ាក់ ស៊ុនដារ៉ាវេត បានបង្ខំចិត្តរត់ចេញពីកន្លែងធ្វើការនៅវិមានរដ្ឋាភិបាល ដើម្បីគេចពីការប្រឈមមុខនឹងហ្វូងបាតុកររាប់ម៉ឺននាក់ដែលបានទាមទារឱ្យគាត់ចុះចេញពីតំណែង។ បាតុករដែលប្រកាសខ្លួនថាជាអ្នករាជានិយម ហើយស្មោះស្ម័គ្រចំពោះព្រះមហាក្សត្រ ឬស្តេចសៀម បានចោទប្រកាន់ សាម៉ាក់ ស៊ុនដារ៉ាវេត ថាជាអាយ៉ងរបស់នាយករដ្ឋមន្ត្រីធ្លាក់ពីតំណែង ថាក់ស៊ិន ស៊ីណាវ៉ាត្រា ដែលបាតុករចោទប្រកាន់ថា ជាជនក្បត់ជាតិ ហើយបានគេចខ្លួនទៅប្រទេសអង់គ្លេសនោះ។

ព្រឹត្តិការណ៍ជ្រួលច្របល់នយោបាយនៅទីក្រុងបាងកក ក៏ត្រូវបាននាយករដ្ឋមន្ត្រីសៀម

តទៅទំព័រ៣ ស

តមកពីទំព័រ១ ក

**យកអាសនៈសភា២៩ទៀតពីគណបក្សប្រឆាំង ពោលគឺគណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សបានទៀត ឬអត់ ? ការចង់ដឹងបែបនេះ ក៏ដោយសារតែថ្មីៗនេះ ទាំង ហ៊ុន សែន ក៏ដូចជាអ្នកនយោបាយជាន់ខ្ពស់ជាក្រុមអែបអបរបស់គាត់ទាំង ជាម យៀប ងួន ញ៉ិល បានរំលឹកនិយាយអំពីសេចក្តីប្រាថ្នា និងប្លន់យកអាសនៈសភាទាំង២៦របស់គណបក្សសមរង្ស៊ី និង៣ទៀតពីគណបក្សសិទ្ធិមនុស្ស បើគណបក្សទាំងពីរធ្វើពហិការមិនចូលរួមប្រជុំសភានៅថ្ងៃដំបូង ទី២៤ ខែកញ្ញាខាងមុខនេះ។**

**តាមមតិរបស់ពួកអ្នកសង្កេតការណ៍ថាមហិច្ឆតាអំណាចផ្តាច់មុខឈានទៅរកការគ្រប់គ្រងប្រទេសបែបផ្តាច់ការរបស់ហ៊ុនសែន ដែលភ័យខ្លួនទាំងការប្រឈមមុខនឹងកម្លាំងផ្ទៃក្នុងគណបក្សប្រជាជនខ្លួនឯង ដូចដែលគាត់នេះបានបង្កើតអង្គរក្សឯកជនជាង៦ពាន់នាក់នោះ ពិតជាមិនមានអ្វីវាស់ស្ទង់បានទេ។ ដូចគ្នាដែរ ហ៊ុន សែន បានបង្ហាញនូវមហិច្ឆតាប្រាថ្នាចង់ធ្វើនាយករដ្ឋមន្ត្រីអស់មួយជីវិត ក៏ជារឿងនៃសេចក្តីលោភលន់ហួសហេតុគ្មានការខ្មាស់អៀនចំពោះមុខប្រជារាស្ត្រដែលចង់បានប្រព័ន្ធរបបប្រជាធិបតេយ្យ សេរី ត្រឹមត្រូវ ពិតប្រាកដ។ ប៉ុន្តែថា បើ ហ៊ុន សែន ហ៊ានអនុវត្តដោយជាក់ស្តែងនូវផែនការបំភ្លៃច្បាប់ តាមរយៈការប្រើក្រុមប្រឹក្សាធម្មនុញ្ញជាឧបករណ៍របស់ខ្លួនដើម្បីប្លន់យកអាសនៈសភាទាំង២៩មែននោះ ប្រាកដណាស់ ប្រជារាស្ត្រខ្មែរ និងសហគមន៍អន្តរជាតិនឹងធ្វើការថ្កោលទោស។ ហើយនោះ ចង់ឬមិនចង់អ្វីដែល ហ៊ុន សែន គណបក្សប្រជាជនបានអួតនិងអះអាងថាជាមហាជោគជ័យរបស់ខ្លួននៅឯការបោះឆ្នោតកន្លងទៅនោះ ក៏ក្លាយទៅជាសៅហ្មង ប្រឡូកប្រឡាក់ដោយគ្រឿងស្មោគគ្រោកនៃមហិច្ឆតានយោបាយឥតអៀនខ្មាស់ ដែលប្រាថ្នាចង់បានតែអំណាច ទាំងរំលោភបំពានលើឆន្ទៈ និងសិទ្ធិរបស់ប្រជារាស្ត្រ។**

**ពិភពលោកមិនអនុញ្ញាតឱ្យគណបក្សប្រជាជន ហ៊ុនសែនអនុវត្តផែនការគឃ្លើនធ្វើការប្លន់យកអាសនៈសភារបស់គេឯងតាមតែអំពើចិត្តខ្លួននោះទេ បើទោះបីជាតាមគោលការណ៍ច្បាប់អន្តរជាតិ កម្ពុជា ជារដ្ឋអធិបតេយ្យក៏ដោយនោះ។ នេះពីព្រោះមេរៀនដែលជាគំរូអាក្រក់នៃរបៀបរបបផ្តាច់ការយោធានៅប្រទេសភូមាធ្វើឱ្យពិភពលោកមានកង្វល់។ ហើយដូច្នេះពិភពលោកនឹងមិនអនុញ្ញាតឱ្យគណបក្សប្រជាជន ជាពិសេស ហ៊ុន សែន អូសទាញកម្ពុជាទម្លាក់ទៅក្នុងអំណាចផ្តាច់ការឡើយ។**

**រឿងអស់នេះបើ ហ៊ុន សែន គណបក្សប្រជាជនចង់ដឹងច្បាស់ ទាល់តែសាកល់មើល តើនឹងមានប្រតិកម្មក្តៅយ៉ាងណាពីសហគមន៍អន្តរជាតិ។ ហើយ ហ៊ុន សែន គណបក្សប្រជាជន មិនត្រូវធ្វើការស្រមើស្រមៃថា តែប៉ុន្មានឆ្នាំទៀតដល់ឆ្នាំ២០១១ ខ្លួននឹងអាចគ្រប់គ្រងចាត់ចែងបែងចែកតាមអំពើចិត្តនូវប្រាក់ចំណូលរដ្ឋត្រូវបានពីប្រភពប្រេង និងឧស្ម័នធម្មជាតិរាប់ម៉ឺនលានដុល្លារនោះ។**

**គេរឹតតែលែងពិបាកយល់នូវការពិតទៅហើយថា ហេតុអ្វីបានជា ហ៊ុន សែន ជ្រើសរើសពង្រីកចំនួនកងទាហានអង្គរក្សឯកជនរបស់ខ្លួនដល់ទៅ៦ពាន់នាក់នៅពេលដែលប្រទេសកម្ពុជាត្រូវ ហ៊ុន សែន ខ្លួនឯងប្រកាសថា ប្រទេសពោរពេញទៅដោយសុវត្ថិភាព និងស្ថេរភាពស្ទើរតែ១០០% ហើយនឹងមានសន្តិសុខគ្រប់ទីកន្លែងនោះ ? នោះគឺ ម្យ៉ាងមកពី ហ៊ុន សែន ប្រាកដជាធុំក្លិនអំពីការប្រកួតប្រជែងផ្ទៃក្នុងគណបក្សប្រជាជនដែលមិនចង់ឃើញហ៊ុនសែនក្លាយទៅជាមេចំណែកដ៏ធំសព្វបែបយ៉ាង តាមការបែងចែកអំណាចក្នុងរដ្ឋាភិបាល និងការបែងចែកទ្រព្យធនធានរបស់ប្រទេស បម្រើមហិច្ឆតាអំណាចរបស់បុគ្គលខ្លួននោះ។ ហើយគោលដៅធំរបស់ ហ៊ុន សែន នោះ គឺដើម្បីនឹងអាចមានអំណាចត្រួតត្រាកាន់កាប់វាសនារបស់ប្រទេស និងទ្រព្យសម្បត្តិធនធានក្នុងតម្លៃរាប់ម៉ឺនសែនលានដុល្លារដូចជាពីប្រាក់ចំណូលប្រេងកាតដែលកម្ពុជាត្រូវបាននៅប៉ុន្មានឆ្នាំខាងមុខនេះ គាត់នេះមើលឃើញថា មានតែការពង្រីកកម្លាំង ជាពិសេសកម្លាំងអង្គរក្សឯកជនរបស់ខ្លួនដើម្បីការពារបុគ្គលខ្លួនគាត់ និងជាការមិនទុកចិត្តដល់កងកម្លាំងទាំងអស់ផ្នែកយោធា អាវុធហត្ថ និងប៉ូលិស សូម្បីតែនៅក្រោមអំណាចរបស់ខ្លួនជានាយករដ្ឋមន្ត្រីក៏ដោយនោះ។**

**ទាំងនេះទៀតសោតរឹតតែបង្ហាញឱ្យគេឃើញច្បាស់ថា កម្ពុជាបើពុំមានការកែទម្រង់ឱ្យដើរតាមផ្លូវប្រជាធិបតេយ្យត្រឹមត្រូវទេនោះ ហ៊ុន សែន និងយកប្រទេសនេះធ្វើជាចំណាប់នយោបាយអំណាចរបស់ខ្លួនអស់មួយជីវិត ។ហើយការលក់ទ្រព្យធនធានរបស់ប្រទេសក៏នឹងត្រូវពួកគណបក្សកាន់អំណាចនៃមនុស្សមួយក្រុមតូចនេះ រួមទាំងអំពើពុករលួយបក្ខពួកគេបំផ្លាញអាចធ្វើឱ្យកម្ពុជាក្លាយទៅជារងបណ្តាសារប្រេងកាតដូចជានៅប្រទេសនីហ្សេរីយ៉ា នៃទ្វីបអាហ្វ្រិកជាមិនខាន។**

**ដូច្នេះហើយគេមិនមានការងឿងឆ្ងល់នោះឡើយថា ហ៊ុន សែន បើទោះបីជាមានកងអង្គរក្សឯកជន៦ពាន់នាក់ក្នុងដៃអាចបញ្ជាឱ្យធ្វើអ្វីនៅម៉ោងណាក៏បាន និងគាត់នេះអួតអាងអំពីខ្លួនជានាយករដ្ឋមន្ត្រីមានអំណាចបញ្ជាលើកងកម្លាំងប្រដាប់អាវុធទាំងអស់របស់ប្រទេសក៏ដោយ ក៏ ហ៊ុន សែន មិនងាយនឹងសាកល្បងចេញមុខដើរតួរជាមេដឹកនាំប្លន់យកអាសនៈសភាទាំង២៩ពីគណបក្សប្រឆាំងនោះទេ៕**